# ជំហានទាំងប្រាំមួយសម្រាប់ជីវសន្តិសុខកសិដ្ឋាន

## ការរៀបចំ និងការអនុវត្តផែនការជីវសន្តិសុខរបស់អចលនទ្រព្យរបស់អ្នក



### ជំហានទី 1

**គូសផែនទីអចលនទ្រព្យរបស់អ្នក**

បង្កើតចេញជារូបភាពតំបន់សំខាន់ៗ ចំណុចច្រកចូល/ច្រកចេញ។



### ជំហានទី 2

**កំណត់ហានិភ័យជីវសន្តិសុខ និងសកម្មភាពកាត់បន្ថយ**

សត្វចង្រៃ ជំងឺ ស្មៅចង្រៃ និងគន្លងផ្លូវរបស់វា។




### ជំហានទី 3

**ផ្តល់អាទិភាព**

បង្កើតយុទ្ធសាស្ត្រ
ការធ្វើចត្តាឡីស័ក អនាម័យ ការត្រួតពិនិត្យ និងការតាមដានសត្វចង្រៃ។

ផ្តល់អាទិភាពលើសកម្មភាពនានា
ផ្តោតលើតំបន់ដែលមានហានិភ័យខ្ពស់។

# ជំហានទាំងប្រាំមួយសម្រាប់ជីវសន្តិសុខកសិដ្ឋាន



**ជំហានទី 4**

### អនុវត្តផែនការជីវសន្តិសុខរបស់អ្នក

ដាក់ផែនការឱ្យដំណើរការ
ធានាការអនុលោមភាព។

ថែរក្សាកំណត់ត្រា
តាមដានសកម្មភាព និងអន្តរាគមន៍នានា។



**ជំហានទី 5**

### ទំនាក់ទំនងអំពីការរំពឹងទុកនានា

ចែករំលែកផែនការ
បណ្តុះបណ្តាលមនុស្សគ្រប់រូបអំពីនីតិវិធី និងតួនាទីរបស់ពួកគេ។

ប្រើផ្លាកសញ្ញាច្បាស់លាស់
រម្លឹកមនុស្សអំពីពិធីសារនានា។



**ជំហានទី 6**

### ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការរបស់អ្នក

ការត្រួតពិនិត្យជាប្រចាំ ការវិភាគកំណត់ត្រា និងសម្រប
តាមតម្រូវការ។ យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ
ឬបន្ទាប់ពីឧប្បត្តិហេតុមួយដែលជាផ្នែកមួយនៃការរៀបចំ
ផែនការអាជីវកម្ម។

# គូសផែនទីអចលនទ្រព្យរបស់អ្នក

**តើសត្វចង្រៃ និងជំងឺនានាអាចរីករាលដាលលើអចលនទ្រព្យរបស់អ្នកដោយរបៀបណា?**

ផែនទីអចលនទ្រព្យគឺចាំបាច់សម្រាប់ផែនការជីវសន្តិសុខកសិដ្ឋាន ដោយរំលេចនូវលក្ខណៈពិសេសសំខាន់ៗដូចជាចំណុចច្រកចូល ផ្ទះ រោងសម្ភារៈ និងកន្លែងលាងសម្អាត។

**នៅលើផែនទីអចលនទ្រព្យរបស់អ្នក សូមគូសបញ្ជាក់យ៉ាងច្បាស់អំពីព្រំប្រទល់ និងសម្គាល់ចំណុចខាងក្រោម៖**

- ☐ **តំបន់ចេញចូល –** សម្រាប់យានយន្ត និងមនុស្ស (បុគ្គលិក អ្នកទស្សនា ការដឹកជញ្ជូន/ការទទួល គ្រឿងបរិក្ខារ)។
- ☐ **តំបន់បែងចែក –** ចំណតរថយន្ត និងផ្លូវយានយន្តដែលប្រើសម្រាប់ចូលទៅកាន់ផ្នែកផ្សេងៗនៃអចលនទ្រព្យ។
- ☐ **តំបន់កសិកម្ម ឬតំបន់ផលិតកម្ម –** នេះគឺជាតំបន់ដែលបុគ្គលិក យានយន្ត គ្រឿងចក្រ និងគ្រឿងបរិក្ខារធ្វើប្រតិបត្តិការ។ មិនអាចចូលតំបន់នេះបានទេ បើគ្មានការប្រើប្រាស់វិធានការអនាម័យសមស្រប។
- ☐ គន្លងផ្លូវហានិភ័យបន្ថែមដែលសត្វចង្រៃ និងជំងឺនានាអាចចូលបាន (សូមមើលគន្លង*ផ្លូវហានិភ័យទាំងប្រាំមួយនៅទំព័រទី 3*)។
- ☐ ទីតាំងល្អបំផុតសម្រាប់gateច្រកទ្វារ និងសញ្ញាផ្សេងទៀត ដើម្បីធ្វើទំនាក់ទំនងលើវិធានការកាត់បន្ថយហានិភ័យ។
- ☐ **តំបន់សម្អាត និងលាងសម្លាប់មេរោគ –** សម្រាប់មនុស្ស គ្រឿងបរិក្ខារ និងគ្រឿងចក្រ។

***ឧទាហរណ៍ផែនទីអចលនទ្រព្យ សូមមើលរូបភាពទី 1។***




**រូបភាពទី 1៖** ឧទាហរណ៍ផែនទីអចលនទ្រព្យ

**សោ**

- តំបន់លាងសម្អាតយានយន្ត
- អាងលាងសម្អាតជើង
- សៀវភៅ/កម្មវិធី App ចុះឈ្មោះចូល
- តំបន់ផ្លាស់សម្លៀកបំពាក់
- ផ្លាកសញ្ញាជីវសន្តិសុខ

# គូសផែនទីអចលនទ្រព្យរបស់អ្នក

## ការកំណត់តំបន់អចលនទ្រព្យ

ការបែងចែកកសិដ្ឋានរបស់អ្នកទៅជាតំបន់គ្រប់គ្រងផ្សេងៗគ្នា បង្កើតបានជាប្រព័ន្ធមួយនៅលើកសិដ្ឋានរបស់អ្នកដែលរៀបជាជាន់ថ្នាក់ និងធ្វើឱ្យរីករាលដាលហានិភ័យនៅទូទាំងចំណុចជាច្រើន។ ប្រព័ន្ធបីតំបន់ជួយបង្កើតការបំបែក និងទទួលស្គាល់ការគ្រប់គ្រងផ្សេងៗគ្នាដែលត្រូវការរវាងតំបន់ផ្សេងៗនៅលើអចលនទ្រព្យ ឧទាហរណ៍ អ្នកទស្សនាដែលចូលក្នុងផ្ទះនឹងមានកម្រិតហានិភ័យខុសគ្នាពីមនុស្សដែលចូលទៅកាន់ទីវាល និងតំបន់ផលិតកម្មនានា។

| តំបន់ | តើវាជាអ្វី? | ឧទាហរណ៍ | សកម្មភាពជីវសន្តិសុខដែលបានណែនាំ |
|---|---|---|---|
| **តំបន់ត្រជាក់ល្មម** | តំបន់ដែលអ្នកទស្សនាអាចចូលទៅកាន់អចលនទ្រព្យ ប៉ុន្តែមានការប៉ះពាល់តិចតួចបំផុត ឬគ្មានការប៉ះពាល់ដំណាំ។ | តម្រូវឱ្យមានសកម្មភាពតិចតួច។ មិនចាំបាច់ដាក់កំណត់លើការចូល។ | តម្រូវឱ្យមានសកម្មភាពតិចតួច។ |
| **តំបន់កក់ក្តៅ** | តំបន់ដែលមនុស្ស និងយានយន្តមួយចំនួនអាចត្រូវចូលទៅ ដើម្បីទម្លាក់ធនធានសម្ភារៈ និង/ឬទទួលយកផលិតផល។ | តំបន់កក់ក្តៅគឺជា 'ផ្លូវថ្នល់' សម្រាប់យានយន្តសំខាន់ៗដែលត្រូវចូលមកក្នុងកសិដ្ឋាន។ តំបន់នេះអាចរួមបញ្ចូលផ្លូវឆ្លងកាត់កសិដ្ឋានទៅកាន់រោងសម្ភារៈនានា។ ឧទាហរណ៍៖ ឡានដឹកទំនិញដែលដឹកយកផលិតផលដំណាំ ទម្លាក់ចុះជី ឬការដឹកជញ្ជូនប្រេងឥន្ធនៈ។ | ការកំណត់លើការចូលប្រហែលជាមិនអាចអនុវត្តបានទេ។ ត្រូវប្រាកដថារក្សាតំបន់នេះឱ្យបានស្អាត ហើយល្អបំផុតគឺក្រាលក្រួសឱ្យបានរាបស្មើ។ តាមដានជាប្រចាំនូវស្មៅចង្រៃ និងសត្វចង្រៃ។ |
| **តំបន់ក្តៅ** | នេះគឺជាតំបន់នៃទីតាំងផលិតកម្មដំណាំ ហើយដែលយានយន្ត គ្រឿងចក្រ និងគ្រឿងបរិក្ខារធ្វើប្រតិបត្តិការ។ | តំបន់ក្តៅគឺសម្រាប់យានយន្ត គ្រឿងចក្រ និងឧបករណ៍ ប៉ុន្តែពួកគេត្រូវតែចាត់វិធានការសមស្របមុនពេលចូល។ ឧទាហរណ៍ មិនគួរផ្លាស់ទីគ្រឿងចក្រចូល ឬចេញពីតំបន់ដោយគ្មានការប្រុងប្រយ័ត្ននោះទេ។ សហគ្រាសធំៗ ឬអ្នកដែលគ្រប់គ្រងជំងឺជាក់លាក់អាចត្រូវការតំបន់ក្តៅដាច់ដោយឡែកនៅក្នុងអចលនទ្រព្យ។ | ដាក់កម្រិតការចូលទៅកាន់តំបន់នេះ។ អនុវត្តចំពោះមនុស្ស ឬយានយន្តនានាដែលមានតម្រូវការដើម្បីចូល។ វិធានការ **មកស្អាត ទៅស្អាត**។ ចូលមើល **dpi.nsw.gov.au/biosecurity/plant/come-clean-go-clean**។ |

### ផ្លូវចេញចូលសម្រាប់ស្ថាប័នផ្តល់សេវាកម្មចាំបាច់ និងសេវាកម្មផ្សេងទៀត

រៀបចំផែនការចូលសម្រាប់**ស្ថាប័នផ្តល់សេវាកម្មចាំបាច់** និង**អ្នកម៉ៅការរបស់ពួកគេ** ហើយផ្តល់ផ្លូវនានាដែលបានណែនាំសម្រាប់កម្មករដើម្បីធ្វើដំណើរចូលទៅកានទីនោះ។ ពិចារណាអំពីទីតាំងនៃបង្គោល/គ្រឿងដាក់ភ្ជាប់សេវាកម្មចាំបាច់និងហានិភ័យពាក់ព័ន្ធនានា។




**រូបភាពទី 2៖** ឧទាហរណ៍នៃការកំណត់តំបន់អចលនទ្រព្យ

ភាពអាចរកបាននៃធនធាន និងថ្លៃចំណាយគឺជាកត្តាសំខាន់ៗក្នុងការកំណត់ថាតើវិធានការអ្វីខ្លះដែលអ្នកអាចជ្រើសរើសដាក់ឱ្យដំណើរការ។ វាជាការល្អបំផុតក្នុងការវាយតម្លៃហានិភ័យទាំងអស់មុនពេលបន្តដើម្បីធានាថា អ្នកកំពុងកំណត់គោលដៅតំបន់ដែលនឹងមានផលប៉ះពាល់/ផលចំណេញខ្ពស់បំផុតលើការវិនិយោគ។ ការវាយតម្លៃដោយខ្លួនឯងអំពីជីវសន្តិសុខរបស់កសិដ្ឋាននឹងជួយសម្រេចកិច្ចការនោះ។

**សម្រាប់ព័ត៌មានលម្អិតបន្ថែម** សូមចូលមើល farmbiosecurity.com.au/using-property-zoning-to-implement-biosecurity-on-farm។

**ជំហានទី 2**

# កំណត់ហានិភ័យជីវសន្តិសុខ និងសកម្មភាពកាត់បន្ថយ យានយន្ត និងគ្រឿងបរិក្ខារ

**គោលដៅ**

ដើម្បីកាត់បន្ថយលទ្ធភាពនៃយានយន្ត និងគ្រឿងបរិក្ខារ កំពុងចាប់ផ្តើមដំណើរការ និងកំពុងរីករាលដាលសត្វចង្រៃ ជំងឺ និងស្មៅចង្រៃនានាចូលក្នុងអចលនទ្រព្យ។

| វិធានការជីវសន្តិសុខ | ឧទាហរណ៍នៃវិធានការ និងសារៈសំខាន់របស់វា | វិធានការក្នុងការប្រើប្រាស់<br>ជ្រើសរើសជម្រើសមួយ | អាទិភាព<br>ជ្រើសរើសជម្រើសមួយ | សកម្មភាពនានា<br>បញ្ចូលសកម្មភាពនីមួយៗដែលត្រូវការ | ប្រព័ន្ធ QA/ស្ថាប័នផ្តល់សេវាកម្ម<br>រាយបញ្ជីប្រព័ន្ធនានា ឬស្ថាប័នផ្តល់សេវាកម្មដែលមានស្រាប់ |
|---|---|---|---|---|---|
| ចំណុចច្រកចូលសំខាន់មួយទៅកាន់ទីទាំងកសិដ្ឋាន។ | ចំណុចច្រកចូលតែមួយផ្តល់ឱកាសដើម្បីជូនដំណឹងដល់អ្នកទស្សនាអំពីនីតិវិធី និងតាមដានអ្នកដែលកំពុងចូលមកក្នុងអចលនទ្រព្យ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| បំបែកកន្លែងចតរថយន្តពីតំបន់ផលិតកម្ម និងតំបន់វេចខ្ចប់។ | កាត់បន្ថយហានិភ័យនៃការរីករាលដាលនៃសត្វចង្រៃចូលទៅក្នុងតំបន់ផលិតកម្ម។ អ្នកទស្សនា និងបុគ្គលិកចតរថយន្តនៅក្នុងកន្លែងចតរថយន្តដែលបានកំណត់ ហើយមានផ្លាកសញ្ញាសម្រាប់ជូនដំណឹងអំពីរឿងនេះ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| ការសម្អាតយានយន្ត និងគ្រឿងបរិក្ខារមុនពេលវាចាកចេញពីអចលនទ្រព្យរបស់អ្នក ជួយកាត់បន្ថយការរីករាលដាលនៃគ្រាប់ពូជស្មៅចង្រៃ ជំងឺ និងសត្វចង្រៃនានាដែលឆ្លងតាមដី។ | ត្រូវដាក់នៅចំណុចច្រកចូល មុនពេលយានយន្ត/គ្រឿងបរិក្ខារអាចចូលមកក្នុងកសិដ្ឋាន រួមទាំងពេលផ្លាស់ទីពីចលនទ្រព្យកសិដ្ឋាននានា។ វិធីនេះលាងសម្អាតសត្វចង្រៃដែលអាចមាននៅលើយានយន្ត/គ្រឿងបរិក្ខារ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| លក្ខខណ្ឌតម្រូវដើម្បីបង្ហាញថាយានយន្តនានាត្រូវបានលាងសម្អាតមុនពេលចូល។ | បង្កាន់ដៃពីកន្លែងលាងរថយន្ត។<br>*ជម្រើសជំនួសស្ថានីយលាងសម្អាតក្នុងកសិដ្ឋាន។* | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| ផ្លាកសញ្ញាច្រកទ្វារកសិដ្ឋានដែលបង្ហាញព័ត៌មានទំនាក់ទំនងសម្រាប់មនុស្សគ្រប់រូបដែលមកដល់កសិដ្ឋាន ហើយថាពិធីសារជីវសន្តិសុខត្រូវបានដាក់ដំណើរការ។ នេះរួមបញ្ចូលទាំងអ្នកទស្សនាកសិដ្ឋាន អ្នកម៉ៅការ និងបុគ្គលិកទាំងអស់។ | ផ្លាកសញ្ញាជីវសន្តិសុខកសិដ្ឋាននៅចំណុចច្រកចូលនីមួយៗទៅកាន់កសិដ្ឋានបង្ហាញថាវិធានការជីវសន្តិសុខកសិដ្ឋានត្រូវបានដាក់ដំណើរការ។ ផ្លាកសញ្ញាក៏អាចត្រូវបានប្រើដើម្បីដឹកនាំចរាចរណ៍ទៅកាន់តំបន់ដែលបានកំណត់ផងដែរ។<br>*សូមមើលចំណុចបន្ទាប់ផងដែរ។* | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| ប្រើផ្លូវយានយន្តដែលមានស្រាប់នៅលើកសិដ្ឋាន។ | ការកំណត់ចលនាយានយន្តជួយកាត់បន្ថយហានិភ័យនៃការរីករាលដាលសត្វចង្រៃ/ជំងឺនានាចូលទៅក្នុងតំបន់ដំណាំ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |

**ជំហានទី 2**

# បុគ្គលិក និងអ្នកទស្សនាកសិដ្ឋាន

**គោលដៅ**

ដើម្បីធានាថាមនុស្សដែលចូលទៅក្នុងកសិដ្ឋានមិននាំយក ឬចម្លងសត្វចង្រៃឆ្លងតាមរុក្ខជាតិ ជំងឺ ឬស្មៅចង្រៃ ហើយដឹងអំពីលក្ខខណ្ឌតម្រូវជីវសន្តិសុខរបស់កសិដ្ឋាន។

| វិធានការជីវសន្តិសុខ | ឧទាហរណ៍នៃវិធានការ និងសារៈសំខាន់របស់វា | វិធានការក្នុងការប្រើប្រាស់<br>ជ្រើសរើសជម្រើសមួយ | អាទិភាព<br>ជ្រើសរើសជម្រើសមួយ | សកម្មភាពនានា<br>បញ្ចូលសកម្មភាពនីមួយៗដែលត្រូវការ | ប្រព័ន្ធ QA/ស្ថាប័នផ្តល់សេវាកម្ម<br>រាយបញ្ជីប្រព័ន្ធនានា ឬស្ថាប័នផ្តល់សេវាកម្មដែលមានស្រាប់ |
|---|---|---|---|---|---|
| **អ្នកទស្សនាចុះឈ្មោះចូលក្នុងបញ្ជីចុះឈ្មោះ។** | កម្មវិធី app ចុះឈ្មោះចូល ឬបញ្ជីចុះឈ្មោះអ្នកទស្សនាជាក្រដាសស្នាម ដើម្បីកត់ត្រាអ្នកណានឹងចូលមកក្នុងអចលនទ្រព្យ និងពេលណាដែលពួកគេចាកចេញ។ នេះអាចជួយក្នុងការតាមដាន ប្រសិនបើរកឃើញសត្វចង្រៃ/ជំងឺថ្មីនៅក្នុងកសិដ្ឋាន។ នេះអាចរួមបញ្ចូលទាំងការសួរពួកគេថាតើថ្មីៗនេះ ពួកគេបានទៅកសិដ្ឋានផ្សេងទៀតដែរឬទេ។ វាក៏ជាឱកាសមួយដើម្បីទំនាក់ទំនងអំពីលក្ខខណ្ឌតម្រូវជីវសន្តិសុខកសិដ្ឋានណាមួយផងដែរ។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **ស្ថានីយសម្អាតគ្រឿងសម្រាប់ពាក់នៅជើងនៅចំណុចច្រកចូលទៅក្នុងតំបន់ផលិតកម្មសម្រាប់អ្នកទស្សនានា។** | នេះកាត់បន្ថយហានិភ័យនៃសត្វចង្រៃដែលឆ្លងចូលទៅក្នុង និងជុំវិញកសិដ្ឋាន។<br>អ្នកទស្សនាក៏អាចយកស្បែកជើងកវែងផ្ទាល់ខ្លួនរបស់ពួកគេ ឬផ្លាស់ប្តូរស្បែកជើងកវែងរបស់ពួកគេនៅពេលមកដល់ផងដែរ។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **ស្ថានីយសម្អាតគ្រឿងសម្រាប់ពាក់នៅជើង និងឧបករណ៍/គ្រឿងបរិក្ខារសម្រាប់បុគ្គលិក។** | កន្លែងលាងសម្អាតជើង ឬថ្នាំបាញ់នៅចំណុចច្រកចូលទៅក្នុងតំបន់ផលិតកម្មកសិដ្ឋានផ្សេងៗគ្នា។ ឧទាហរណ៍ រវាងប្លុក និងអចនទ្រព្យកសិដ្ឋាននានា។ ឬបង្កើតជាកញ្ចប់មួយចំនួនសម្រាប់បុគ្គលិកយកតាមខ្លួន និងប្រើប្រាស់។ នេះជួយកាត់បន្ថយការរីករាលដាលនៃសត្វចង្រៃនៅជុំវិញកសិដ្ឋាន។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **បណ្តុះបណ្តាលបុគ្គលិកអំពីវិធានការជីវសន្តិសុខកសិដ្ឋាន (ល្អបំផុតជាផ្នែកមួយនៃដំណើរការណែនាំបុគ្គលិកថ្មី)។** | នេះអាចរួមបញ្ចូលវិធានការមួយចំនួនដែលបានកំណត់នៅក្នុងបញ្ជីត្រួតពិនិត្យនេះ ដូចជាអ្វីដែលត្រូវធ្វើនៅពេលមក និងទៅកាន់ផ្នែកផ្សេងៗនៃកសិដ្ឋាន អ្វីដែលត្រូវរកមើល របៀបរាយការណ៍។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **ផ្តល់លទ្ធភាពដល់បុគ្គលិកក្នុងការទទួលបានឧបករណ៍ និងធនធាននានាដើម្បីសម្លាប់មេរោគជាប់គ្រឿងពាក់ជើង ឧបករណ៍ និងគ្រឿងបរិក្ខារដើម្បីឱ្យពួកគេមានអ្វីដែលពួកគេត្រូវការដើម្បីប្រតិបត្តិការវិធានការល្អបំផុត។** | ផ្តល់ច្រាស់ដុសស្បែកជើង និងដបបាញ់ដែលមានផ្ទុកថ្នាំសម្លាប់មេរោគ ដើម្បីឱ្យបុគ្គលិកអាចសម្អាតគ្រឿងសម្រាប់ពាក់នៅជើង និងឧបករណ៍រវាងប្លុកនានា។ ធនធានដើម្បីជួយក្នុងការកំណត់អត្តសញ្ញាណសត្វចង្រៃ/ជំងឺនានា និងអ្វីដែលត្រូវធ្វើប្រសិនបើពួកគេរកឃើញវា។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **តើមានរបស់របរដែលមិនត្រូវបានអនុញ្ញាតឱ្យយកមកចូលក្នុងទីតាំងដែរឬទេ?** | អាចមានរបស់របរដែលមិនត្រូវបានអនុញ្ញាតឱ្យយកមកចូលក្នុងទីតាំងដោយហេតុផលសុខភាព សុវត្ថិភាព ឬហេតុផល QA ផ្សេងទៀត។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |

ជំហានទី 2

# ធនធានសម្ភារៈកសិដ្ឋាន

**គោលដៅ**

ដើម្បីធានាថាផលិតផលដែលចូលមកក្នុងកសិដ្ឋានមិនមានសត្វចង្រៃ ជំងឺ និងស្មៅចង្រៃនៅលើអចលទ្រព្យនោះ។

| វិធានការជីវសន្តិសុខ | ឧទាហរណ៍នៃវិធានការ និងសារៈសំខាន់របស់វា | វិធានការក្នុងការប្រើប្រាស់<br>ជ្រើសរើសជម្រើសមួយ | អាទិភាព<br>ជ្រើសរើសជម្រើសមួយ | សកម្មភាពនានា<br>បញ្ចូលសកម្មភាពនីមួយៗដែលត្រូវការ | ប្រព័ន្ធ QA/ស្ថាប័នផ្តល់សេវាកម្ម<br>រាយបញ្ជីប្រព័ន្ធនានា ឬស្ថាប័នផ្តល់សេវាកម្មដែលមានស្រាប់ |
|---|---|---|---|---|---|
| **សម្ភារៈដាំដុះ និងគ្រាប់ពូជដែលមានប្រភពមកពីអ្នកផ្គត់ផ្គង់ដែលមានកេរ្តិ៍ឈ្មោះល្អ។** | ស្វែងរកធនធានសម្ភារៈអ្នកផ្គត់ផ្គង់ដែលមានវិធានការជីវសន្តិសុខល្អ។ នេះកាត់បន្ថយហានិភ័យនៃសត្វចង្រៃដែលត្រូវបានណែនាំតាមរយៈសម្ភារៈដាំដុះ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **សម្ភារៈដាំដុះត្រូវបានត្រួតពិនិត្យនៅពេលមកដល់សម្រាប់សត្វចង្រៃឆ្លងតាមរុក្ខជាតិ រោគសញ្ញាជំងឺ និងស្មៅចង្រៃនានា។** | កត់ត្រាប្រសិនបើសម្ភារៈដាំដុះមានសត្វចង្រៃ ឬរោគសញ្ញាជំងឺ ឬស្មៅចង្រៃ ឬប្រសិនបើវាស្អាត។ ប្រសិនបើមានសត្វចង្រៃ សូមទាក់ទងអ្នកផ្គត់ផ្គង់ដើម្បីឱ្យពួកគេដឹង។ រាយការណ៍អំពីការប្រទះឃើញអ្វីដែលមិនប្រក្រតីទៅកាន់ **បណ្តាញទូរសព្ទបន្ទាន់អំពីសត្វចង្រៃឆ្លងតាមរុក្ខជាតិដែលនាំចូលពីបរទេស៖ 1800 084 881**។ កំណត់ត្រាទាំងនេះជួយក្នុងការបណ្តុះបណ្តាលក្នុងករណីមានការលុកលុយ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **កត់ត្រាប្រភពនៃធនធានសម្ភារៈ និងពេលវេលាដែលវាត្រូវបានបញ្ជាទិញ និងដឹកជញ្ជូន។** | រក្សាទុកកំណត់ត្រាអំពីប្រភពទំនិញ កាលបរិច្ឆេទនៃការបញ្ជាទិញ និងការដឹកជញ្ជូន រួមទាំងលទ្ធផលនៃការត្រួតពិនិត្យសត្វចង្រៃ/ជំងឺ ទាំងវត្តមាន និងអវត្តមាន។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ជីកំប៉ុស ជីកំប៉ុសគ្របដី និងសារធាតុបន្ថែមត្រូវបានយកមកពីអ្នកផ្គត់ផ្គង់ដែលមានកេរ្តិ៍ឈ្មោះល្អ។** | ស្វែងរកធនធានសម្ភារៈអ្នកផ្គត់ផ្គង់ដែលមានវិធានការជីវសន្តិសុខល្អ។ នេះកាត់បន្ថយហានិភ័យនៃការនាំចូលសត្វចង្រៃថ្មីៗ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **កំណត់ត្រាត្រូវបានរក្សាទុកសម្រាប់ប្រភពនានានៃធនធានសម្ភារៈផ្សេងទៀត។** | រក្សាទុកកំណត់ត្រានៃវិញ្ញាបនបត្រអ្នកផ្គត់ផ្គង់ និងគ្រឿងផ្សំនៃធនធានសម្ភារៈដូចជាជីកំប៉ុស និងជីកំប៉ុសគ្របដី។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ធនធានសម្ភារៈត្រូវបានដឹកជញ្ជូន និងផ្ទុកចេញពីតំបន់ផលិតកម្ម។** | ធនធានសម្ភារៈត្រូវបានផ្ទុកចេញពីតំបន់ផលិតកម្ម ហើយប្រព័ន្ធបង្ហូរទឹកក៏ត្រូវបានបង្វែរចេញពីតំបន់ផលិតកម្មផងដែរ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ទឹកត្រូវបាននាំចូលពីប្រភពស្អាត ឬបានធ្វើប្រព្រឹត្តកម្ម។ ប្រព័ន្ធបង្ហូរទឹកគឺនៅឆ្ងាយពីតំបន់ផលិតកម្ម។** | ទឹកអាចជាប្រភពនៃភ្នាក់ងារបង្ករោគ (ឧទាហរណ៍៖ Pythium, Fusarium, Phytophthora)។ ការធ្វើតេស្តជាប្រចាំអាចត្រូវបានធ្វើឡើងដើម្បីកំណត់ពីបញ្ហានេះ។ កំណត់ត្រានៃវត្តមាន/អវត្តមាននៃសត្វចង្រៃណាមួយគួរតែត្រូវបានរក្សាទុក។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ធនធានសម្ភារៈដូចជាជីកំប៉ុស និងជីកំប៉ុសគ្របដី ត្រូវបានរក្សាទុកឱ្យឆ្ងាយពីតំបន់ផលិតកម្ម ហើយធានាថាប្រព័ន្ធបង្ហូរទឹកណាមួយក៏នៅឆ្ងាយពីតំបន់ផលិតកម្មផងដែរ។** | នេះកាត់បន្ថយហានិភ័យនៃសត្វចង្រៃ/ជំងឺ/ស្មៅចង្រៃដែលអាចកើតមានពីការចូលទៅក្នុងតំបន់ផលិតកម្មតាមខ្យល់ ឬទឹក។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |

ជំហានទី 2

# កាកសំណល់ និងស្មៅចង្រៃ

**គោលដៅ**

កាត់បន្ថយជម្រក និងប្រភពមេរោគ និងសក្តានុពលសម្រាប់ការរីករាលដាលនៃសត្វចង្រៃ ជំងឺ និងស្មៅចង្រៃ។

| វិធានការជីវសន្តិសុខ | ឧទាហរណ៍នៃវិធានការ និងសារៈសំខាន់របស់វា | វិធានការក្នុងការប្រើប្រាស់<br>ជ្រើសរើសជម្រើសមួយ | អាទិភាព<br>ជ្រើសរើសជម្រើសមួយ | សកម្មភាពនានា<br>បញ្ចូលសកម្មភាពនីមួយៗដែលត្រូវការ | ប្រព័ន្ធ QA/ស្ថាប័នផ្តល់សេវាកម្ម<br>រាយបញ្ជីប្រព័ន្ធនានា ឬស្ថាប័នផ្តល់សេវាកម្មដែលមានស្រាប់ |
|---|---|---|---|---|---|
| **ដំណាំ និងស្មៅចង្រៃត្រូវបានត្រួតពិនិត្យជាប្រចាំដើម្បីរកមើលសត្វចង្រៃ។** | ការត្រួតពិនិត្យជាប្រចាំជួយកំណត់អត្តសញ្ញាណអ្វីដែលមិនធម្មតាតាំងពីដំបូង ហើយការរកឃើញបានទាន់ពេលមានន័យថាឱកាសកាន់តែប្រសើរឡើងក្នុងការកាត់បន្ថយផលប៉ះពាល់នៃសត្វចង្រៃ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **កំណត់ត្រាដែលរក្សាទុកអំពីលទ្ធផលត្រួតពិនិត្យ និងវិធានការត្រួតពិនិត្យដែលបានប្រើ និងប្រសិទ្ធភាពរបស់វា។** | កំណត់ត្រានឹងជួយក្នុងការតាមដានការបង្កើតជម្រើសនៃការគ្រប់គ្រង។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **កាកសំណល់ដំណាំត្រូវបានសម្អាត និងបោះចោលឆ្ងាយពីតំបន់ផលិតកម្ម ជាពិសេសប្រសិនបើវារងផលប៉ះពាល់ដោយសត្វចង្រៃ។** | កាកសំណល់ដំណាំអាចផ្តល់ជម្រកដែលសត្វចង្រៃអាចមូលផ្តុំបញ្ចូលមេរោគបន្ថែមដើម្បីឆ្លងដំណាំម្តងទៀត។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ការគ្រប់គ្រងស្មៅចង្រៃត្រូវបានអនុវត្ត (រួមទាំងការត្រួតពិនិត្យ និងការរក្សាទុកកំណត់ត្រា)។** | ស្មៅចង្រៃអាចប៉ះពាល់ដល់ផលិតកម្មដំណាំដោយខ្លួនឯងផ្ទាល់ ប៉ុន្តែក៏អាចផ្តល់រុក្ខជាតិដែលផ្តល់ទីជម្រកសម្រាប់សត្វចង្រៃរស់នៅ និងបន្តពូជផងដែរ ដែលមានន័យថាមានមេរោគបន្ថែមទៀតដើម្បីចម្លងរោគដល់ដំណាំ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ប្រព័ន្ធបង្ហូរទឹកល្អ នាំទឹកសំណល់ចេញពីដំណាំ។** | ការបង្ហូរទឹកចេញពីដំណាំមានន័យថា សត្វចង្រៃដែលមានសក្តានុពលណាមួយនឹងមិនចូលទៅក្នុងតំបន់ផលិតកម្មទេ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |

ជំហានទី 2

# ការវេចខ្ចប់ ធុងសំរាម និងបន្ទះដាក់ទ្រទំនិញ

**គោលដៅ**

ដើម្បីធានាថាសមាសធាតុប្រព័ន្ធផលិតកម្មមានភាពស្អាត និងកាត់បន្ថយហានិភ័យនៃការឆ្លង និងការរីករាលដាលនៃសត្វចង្រៃ និងជំងឺនានា។

| វិធានការជីវសន្តិសុខ | ឧទាហរណ៍នៃវិធានការ និងសារៈសំខាន់របស់វា | វិធានការក្នុងការប្រើប្រាស់<br>ជ្រើសរើសជម្រើសមួយ | អាទិភាព<br>ជ្រើសរើសជម្រើសមួយ | សកម្មភាពនានា<br>បញ្ចូលសកម្មភាពនីមួយៗដែលត្រូវការ | ប្រព័ន្ធ QA/ស្ថាប័នផ្តល់សេវាកម្ម<br>រាយបញ្ជីប្រព័ន្ធនានា ឬស្ថាប័នផ្តល់សេវាកម្មដែលមានស្រាប់ |
|---|---|---|---|---|---|
| **ស្ថានីយសម្អាតគ្រឿងសម្រាប់ពាក់នៅជើងដែលមានរវាងតំបន់ផ្សេងៗគ្នានៅក្នុងកសិដ្ឋាន និងរវាងអចលនទ្រព្យកសិដ្ឋាននានា។** | ការសម្អាតគ្រឿងសម្រាប់ពាក់នៅជើងរវាងតំបន់កសិដ្ឋាន និងអចលនទ្រព្យ កាត់បន្ថយហានិភ័យនៃការរីករាលដាលសត្វចង្រៃជំងឺ និងស្មៅចង្រៃនៅទូទាំងកសិដ្ឋាន។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ឡាំង ធុង បន្ទះដាក់ទ្រទំនិញជាដើម ត្រូវបានលាងសម្អាត និងលាងសម្លាប់មេរោគបន្ទាប់ពីប្រើប្រាស់រួច។** | នេះកាត់បន្ថយការចម្លងសត្វចង្រៃ/ជំងឺ/គ្រាប់ពូជស្មៅចង្រៃ ពីផលិតផលមុនទៅការប្រមូលផលបន្ទាប់។ ប្រសិនបើឡាំង/ធុងជាដើម បានមកពីអចលនទ្រព្យផ្សេងទៀត វាអាចផ្ទុកសត្វចង្រៃថ្មីៗ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ការវេចខ្ចប់ស្អាត ធុង បន្ទះដាក់ទ្រទំនិញ ត្រូវបានរក្សាទុកឱ្យបានត្រឹមត្រូវឆ្ងាយពីតំបន់ផលិតកម្ម។** | នេះកាត់បន្ថយហានិភ័យនៃការចម្លងមេរោគពីតំបន់ផលិតកម្ម។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ឧបករណ៍ និងគ្រឿងបរិក្ខារត្រូវបានលាងសម្លាប់មេរោគបន្ទាប់ពីប្រើប្រាស់រួច និងក្នុងអំឡុងពេលប្រើប្រាស់តាមតម្រូវការ។** | ការសម្អាតឧបករណ៍/គ្រឿងបរិក្ខាររវាងការប្រើប្រាស់ កាត់បន្ថយការចម្លង ឬជំងឺ និងសត្វចង្រៃនានា។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ធានាបាននូវប្រព័ន្ធបង្ហូរទឹកល្អចេញពីតំបន់ផលិតកម្ម ដើម្បីកាត់បន្ថយហានិភ័យនៃសត្វចង្រៃដែលឆ្លងតាមទឹក។** | ទឹកអាចជាប្រភពនៃភ្នាក់ងារបង្ករោគរុក្ខជាតិដែលបង្កជំងឺ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **រោងវេចខ្ចប់ និងគ្រឿងបរិក្ខារត្រូវបានសម្អាត និងលាងសម្លាប់មេរោគជាប្រចាំ និងក្នុងអំឡុងពេលសម្រាកផងដែរ។** | នេះកាត់បន្ថយហានិភ័យនៃការប្រមូលផ្តុំសត្វចង្រៃ/ជំងឺនានា។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ទឹកស្រោចស្រពត្រូវបានធ្វើប្រព្រឹត្តកម្ម/សម្លាប់មេរោគ។** | កំណត់ត្រានៃវត្តមាន/អវត្តមាននៃការរកឃើញណាមួយ គួរតែត្រូវបានរក្សាទុក។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |
| **ការអនុវត្តល្អបំផុតនៅក្នុងថ្នាលផលិតកម្មផ្ទាល់ខ្លួន។** | នេះកាត់បន្ថយហានិភ័យនៃការណែនាំសត្វចង្រៃចូលទៅក្នុងតំបន់ដាំដុះ និងធានាបាននូវការចាប់ផ្តើមជាមួយនឹងដំណាំដែលមានសុខភាពល្អ។ | ○ បាទ/ចាស ○ ទេ<br>○ កំពុងដំណើរការ<br>○ មិនអនុវត្ត | ○ ភ្លាមៗ<br>○ អនាគត<br>○ មិនអនុវត្ត | | |

ជំហានទី 2

# អាកាសធាតុ / ខ្យល់ ភ្លៀង និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ

**គោលដៅ**
គ្រប់គ្រងហានិភ័យដែលទាក់ទងនឹងព្រឹត្តិការណ៍អាកាសធាតុដែលមិននឹកស្មានដល់/ធ្ងន់ធ្ងរ។

| វិធានការជីវសន្តិសុខ | ឧទាហរណ៍នៃវិធានការ និងសារៈសំខាន់របស់វា | វិធានការក្នុងការប្រើប្រាស់<br>ជ្រើសរើសជម្រើសមួយ | អាទិភាព<br>ជ្រើសរើសជម្រើសមួយ | សកម្មភាពនានា<br>បញ្ចូលសកម្មភាពនីមួយៗដែលត្រូវការ | ប្រព័ន្ធ QA<br>រាយបញ្ជីប្រព័ន្ធដែលបានអនុវត្តដែលមានស្រាប់ |
|---|---|---|---|---|---|
| **តាមដាន និងស្ទង់មតិដំណាំជាប្រចាំ។** | ការត្រួតពិនិត្យជាប្រចាំជួយកំណត់អត្តសញ្ញាណអ្វីដែលមិនធម្មតាតាំងពីដំបូង ហើយការរកឃើញបានទាន់ពេលមានន័យថាឱកាសកាន់តែប្រសើរឡើងក្នុងការកាត់បន្ថយផលប៉ះពាល់នៃសត្វចង្រៃ។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **ប្រើអន្ទាក់ដើម្បីជួយឃ្លាំមើល។** | អន្ទាក់អាចកាត់បន្ថយតម្រូវការធនធានកម្លាំងពលកម្ម និងអាចមានភាពឡាក់លាក់ជាងមុន និងអាចរកឃើញសត្វចង្រៃ។ កត់ត្រាវត្តមាន/អវត្តមាននៃសត្វចង្រៃ។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **បណ្តុះបណ្តាលបុគ្គលិកឱ្យយល់ដឹងអំពីសត្វចង្រៃដែលឆ្លងតាមរុក្ខជាតិទូទៅ និងនាំចូលពីបរទេស។** | តាមរយៈការដឹងពីអ្វីដែលជាធម្មតាមាននៅទីនោះ បុគ្គលិកក៏នឹងអាចសម្គាល់និងរាយការណ៍អំពីអ្វីដែលមានលក្ខណៈមិនប្រក្រតីផងដែរ។ នេះមានន័យថាមានឱកាសឆ្លើយតបទៅនឹងសត្វចង្រៃបានកាន់តែលឿន។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **រាយការណ៍អំពីសត្វចង្រៃដែលតែងតែជួបប្រទះ។** | ការរាយការណ៍បានកាន់តែលឿនមានន័យថាការឆ្លើយតបក៏កាន់តែលឿនក្នុងការគ្រប់គ្រងសត្វចង្រៃផងដែរ។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |
| **កត់ត្រាព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ (ឧទាហរណ៍ ទឹកជំនន់ ព្យុះមានធូលី) និងតាមដានការត្រួតពិនិត្យនៅកសិដ្ឋានសម្រាប់សញ្ញាថ្មីៗនៃស្មៅចង្រៃ ជំងឺនានាជាដើម។** | ព្រឹត្តិការណ៍អាកាសធាតុអាចបង្ហាញពីបញ្ហាប្រឈមជីវសន្តិសុខផ្សេងៗគ្នា។ ការយល់ដឹងអំពីអ្វីៗទាំងនេះមានន័យថាអ្នកអាចត្រៀមខ្លួនបានកាន់តែប្រសើរឡើងដើម្បីកាត់បន្ថយហានិភ័យ។ | ◯ បាទ/ចាស ◯ ទេ<br>◯ កំពុងដំណើរការ<br>◯ មិនអនុវត្ត | ◯ ភ្លាមៗ<br>◯ អនាគត<br>◯ មិនអនុវត្ត | | |